**សមាគមទេសចរណ៍កម្ពុជា**

Cambodia Tourism Association

# សេចក្តីប្រកាសព័ត៌មាន

**សមាគមទេសចរណ៍កម្ពុជា** (CATA) ក្រោមការដឹកនាំពី **លោកជំទាវប្រធាន ឆាយ ស៊ីវលីន** បានរៀបចំកិច្ចប្រជុំសមាជិកនាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ក្នុងគោលបំណងដើម្បីផ្តល់ឱកាសដល់សមាជិក និងអ្នកប្រកបអាជីវកម្មក្នុងវិស័យទេសចរណ៍ យល់ឱ្យកាន់ច្បាស់អំពីកាតព្វកិច្ចពន្ធ ការប្រកាសពន្ធ ការអនុវត្តអោយអនុលោមតាមច្បាប់នានា ការបង្កើតឱកាសទំនាក់ទំនងផ្ទាល់ជាមួយក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកច្បាប់ និងពន្ធ និងប្រើប្រាស់សេវាកម្មពីក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកច្បាប់ និងពន្ធប្រកបដោយទំនុកចិត្ត។

កម្មវិធីនេះប្រព្រឹត្តទៅក្រោមប្រធានបទ **ការអនុលោមយ៉ាងឆ្លាតវៃ៖ តួនាទីរបស់អ្នកជំនាញពន្ធ និងច្បាប់** **Smart Compliance: The Role of Tax & Legal Professionals** នៅសណ្ឋាគារ Capri by Fraser Phnom Penh

កម្មវិធីបានប្រព្រឹត្តទៅដោយជោគជ័យ ដោយមានការចូលរួមលើកឡើងពីបញ្ហាប្រឈមនានា ការកង្វះខាតនូវព័ត៌មាន វិធិសាស្រ្តក្នុងការដោះស្រាយបញ្ហាទៅតាមកាលៈទេសៈផ្សេងៗ។ ក្រោមការចូលរួមពីថ្នាក់ដឹកនាំសមាគមទេសចរណ៍កម្ពុជា (CATA) សមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដាកម្ពុជា (CTAFA) និងការចូលរួមយ៉ាងសកម្មពីសមាជិកសមាគម បណ្តាក្រុមហ៊ុនទេសចរណ៍ ការីទេសចរ ប្រតិបត្តិករទេសចរណ៍ វិស័យសណ្ឋាគារ និងមានការចូលរួមពីទីភ្នាក់ងារផ្នែកច្បាប់ និងពន្ធ ដែលបានជួយបកស្រាយយ៉ាងច្បាស់លាស់ចំពោះបញ្ហា និងចម្ងល់ផ្សេងៗរបស់សមាជិកក្នុងវិស័យទេសចរណ៍។

សមាគមទេសចរណ៍កម្ពុជា (CATA) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមយ៉ាងសកម្ម និងការគាំទ្រពីសមាជិកទាំងអស់ និងក្រុមហ៊ុនទីភ្នាក់ងារផ្នែកច្បាប់ និងពន្ធ ដែលបានរួមចំណែកសំខាន់ធ្វើឱ្យកម្មវិធីនេះប្រព្រឹត្តទៅដោយជោគជ័យ។ ជាសារបញ្ជាក់អោយឃើញថាកម្មវិធីពិតជាមានសារៈសំខាន់ក្នុងការជួយឱ្យអាជីវករក្នុងវិស័យទេសចរណ៍ មានការយល់ដឹងអំពីការប្រកាសពន្ធ កាតព្វកិច្ចពន្ធ និងការអនុលោមតាមច្បាប់ ដើម្បីជួយសម្រួលដល់ការប្រតិបត្តិអាជីវកម្មនៅក្នុងវិស័យទេសចរណ៍។ **សូមអរគុណ៕**

